តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
<u>សាលក្រម</u>
លេខ ០៨ គ ចុះថ្ងៃទី ០៣
ខែ កុម្ភៈ ឆ្នាំ ២០០៦
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ១០៥ ចុះថ្ងៃទី ០៣
ខែ មីនា ឆ្នាំ ១៩៩៩

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### តាងនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តមានជ័យ នាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ចៅក្រមតុលាការខេត្តបាត់ដំបង

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តបាត់ដំបង

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ១០៥ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

-ឈ្មោះ **ស គម** ហៅ **ឈ ល** ភេទប្រុស អាយុ ៤១ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិឈូក ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ សាសនាព្រះពុទ្ធ កំរិតវប្បធម៌គ្មាន ទីលំនៅមុនពេលចាប់ខ្លួននៅភូមិប្រឡាយ ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប របររកស៊ីធ្វើស្រែ និង កម្មករយាមដី ។ ប្រពន្ធឈ្មោះ **ស ចរ** មានកូន ០២នាក់ ឪពុកឈ្មោះ **ស ម** (ស) ម្តាយឈ្មោះ **ឆ ឆ** (ស) ទោសពីមុន *គ្មាន* ។

ឃុំខ្លួនថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ : <u>ប្លន់</u> ប្រព្រឹត្តនៅភូមិអារញ្ញ ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

មេធាវី **ជឹម តារា** ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ **ស គម** អវត្តមានមានមូលហេតុ ។

-ជនរងគ្រោះឈ្មោះ **ភ រ** ភេទប្រុស អាយុ ៣៨ឆ្នាំ មានទីលំនៅភូមិអារញ្ញ ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប និង ឈ្មោះ **ម ឃ** ភេទប្រុស មិនចូលមកប្តឹងទាមទារជម្ងឺចិត្តទេ ។

*សាលក្រមនេះបានចូលជាស្ថាពរនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៦*
*ដោយពុំមានភាគីណាមួយចូលមកប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ឡើយ ។*
*សៀមរាប.ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
**ក្រឡាបញ្ជី**
**ហត្ថលេខា និង ត្រា**
[redacted]

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

ឈ្មោះ ស គហ, ឈ្មោះ ស ធ, ឈ្មោះ ឆ ព និង ឈ្មោះ ខា ជាទាហានអង្គភាពសាលាស្រុកសៀមរាប ។ នៅអំឡុងឆ្នាំ ១៩៩៩ ពួកគេបានទទួលបញ្ជាចុះទៅយាមល្បាតនៅត្រពាំងពាររាំង ភូមិចុងស្រុក ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប ដើម្បីចាប់អ្នកឆក់ត្រី ។

នៅយប់ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩ ឈ្មោះ ហ ឃ និង ឈ្មោះ ភ រ បានទៅឆក់ត្រីនៅតំបន់វាលក្រោមរហូតដល់ម៉ោង ១២យប់ ទើបត្រឡប់មកផ្ទះវិញ ។ វេលាម៉ោង ០៣ជិតភ្លឺ ឈ្មោះ ស គហ, ឈ្មោះ ស ធ, ឈ្មោះ ឆ ព ស្លៀកពាក់ឯកសណ្ឋានជាទាហាន ចំណែកឈ្មោះ ឲ ពាក់ឯកសណ្ឋានប៉ារ៉ា ដោយមានកាំភ្លើង AK គ្រប់ដៃបានទៅដល់ផ្ទះ ហ ឃ រួចបានយកកាំភ្លើងភ្ជង់សំឡុតឱ្យបិទភ្លើង ហើយដោះចង្កៀងចេញពីក្បាលស្ពាយប្រដាប់ឆក់ត្រីឱ្យដើរទៅគោកជ្រឹង ។ ពេលដើរពីផ្ទះបាន ៥០ម៉ែត្រ ឈ្មោះ ឲ បានសំឡុតទារប្រាក់ពីឈ្មោះ ឃ ត ៦០.០០០៛០០ ( ប្រាំមួយម៉ឺនរៀល ) ឈ្មោះ ហ ឃ ក៏ដើរត្រឡប់មកផ្ទះវិញ ប្រាប់ប្រពន្ធឱ្យរកលុយចំនួន ៦០.០០០៛០០ ( ប្រាំមួយម៉ឺនរៀល ) ឱ្យពួកវា រួចហើយពួកវាក៏បានឱ្យឈ្មោះ ហ ឃ ជូនទៅផ្ទះឈ្មោះ ភ រ ទៀត ។

ពេលមកដល់ផ្ទះ ភ រ ឈ្មោះ ហ ឃ បានស្រែកហៅឈ្មោះ រិទ្ធ ឱ្យចុះមកដី ពេលនោះឈ្មោះ ភ រ បានបើកទ្វារ ឈ្មោះ ស គហ និង បក្សពួកបានយកកាំភ្លើងអាកាភ្ជង់ឱ្យយកឧបករណ៍ឆក់ត្រីចុះមកដី ។ បន្ទាប់មកពួកវាភ្ជង់ពីក្រោយឱ្យដើរទៅត្បូងភូមិជាមួយ និង កូនប្រុសឈ្មោះ ហឿន បានចម្ងាយប្រហែល ១០០០ម៉ែត្រ ទើបឈប់រួចទារប្រាក់ចំនួន ៦០.០០០រៀល ( ប្រាំ...ម៉ឺនរៀល ) ។ ពេលនោះឈ្មោះ ភ រ ក៏បានឱ្យកូនឈ្មោះ ហឿន ដើរត្រឡប់មកផ្ទះវិញ មកប្រាប់ម្ដាយរកលុយបានតែចំនួន ៥០.០០០រៀល ( ប្រាំម៉ឺនរៀល ) ប៉ុណ្ណោះទៅឱ្យឈ្មោះ ស គហ និង បក្សពួករួចពួកវាបានឱ្យឈ្មោះ ភ រ ត្រឡប់មកផ្ទះវិញ ។ ឈ្មោះ ស គហ ត្រូវសមត្ថកិច្ចចាប់ខ្លួនបាននៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៥ ចំណែកបក្សពួកបានរត់គេចខ្លួន បាត់គ្មានសាវតាជាតិ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ស គហ បានឆ្លើយថា នៅឆ្នាំ ១៩៩៩ ខ្លួនត្រូវមេបញ្ជាការឈ្មោះ ឲ ផ បានឱ្យពួកខ្លួនមានគ្នា ០៨នាក់ទៅយាមល្បាតនៅវាលត្រពាំងពាររាំង ភូមិអារញ្ញ ឃុំសៀមរាប ចាំចាប់អ្នកឆក់ត្រី និងអ្នកដាក់ស្បៃមុង ។

នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩ មេក្រុមឈ្មោះ ខា បាននាំខ្លួនឈ្មោះ ស ធ, ឈ្មោះ ឆ ព មកយាមនៅភូមិចុងស្រុក តាមមាត់ស្ទឹង រហូតដល់ម៉ោង ១២យប់ ពួកខ្លួនបានឃើញភ្លើងឆក់ត្រីមានគ្នា ០២នាក់ ពួកខ្លួនបានតាមចាប់ដោយមានគ្នា ០៤នាក់ ០៣នាក់ ស្លៀកឯកសណ្ឋានជាយោធា ឈ្មោះ ខា ពាក់ឯកសណ្ឋានជាប៉ារ៉ាមានកាំភ្លើងអាកាគ្រប់ដៃ ដើរទៅដល់ផ្ទះ ហ ឃ មិនទាន់ដោះភ្លើងចេញពីក្បាល មានស្ពាយប្រដាប់ឆក់ត្រីនៅពីក្រោយខ្នងមានត្រីក្នុងកន្ត្រក់ប្រហែលជា ០៤គីឡូក្រាម ។ ពេលនោះពួកខ្លួនបានភ្ជង់ឱ្យបិទភ្លើង ហើយឱ្យគេដើរទៅកន្លែងគោកជ្រឹង ។ ពួកខ្លួនដើរតាមពីក្រោយបានចម្ងាយពីផ្ទះប្រហែល ៥០ម៉ែត្រ ឈ្មោះ ខា បានសំឡុតឈ្មោះ ហ ឃ យកលុយបាន ៦០.០០០រៀល ( ប្រាំមួយម៉ឺនរៀល ) ។ រួចពួកខ្លួនក៏ឱ្យឈ្មោះ ហ ឃ ជូនទៅផ្ទះ អ្នកឆក់ត្រីម្នាក់ទៀតចម្ងាយប្រហែល ២០០ម៉ែត្រ ។ ពេលទៅដល់ឈ្មោះ ឃិត បានហៅឈ្មោះ ភ រ ។បើកទ្វារ ។ ខ្លួនឃើញត្រីប្រហែល ០៤គីឡូក្រាមនៅក្នុងឡាំង ពួកខ្លួនបានឱ្យចុះមកដីឱ្យដើរទៅកន្លែងពំនូកចំប៉ើងឱ្យឈ្មោះ ហ ឃ ដើរទៅផ្ទះវិញ ។ ឈ្មោះ ខា បានសំឡុតទារប្រាក់ពីឈ្មោះ ភ រ ចំនួន ៦០.០០០រៀល តែបាន ៥០.០០០រៀលទៅឱ្យពួក

ខ្លួនក៏បានយល់ព្រម រួចត្រឡប់មកកន្លែងវិញទៅ ។ ចំពោះលុយយកបាន ១១០.០០០រៀលចែកគ្នាចាយអស់ហើយ ។

-ជនរងគ្រោះឈ្មោះ ភ រ បានឆ្លើយថា កាលពីថ្ងៃខែមិនចាំ ក្នុងឆ្នាំ ១៩៩៩ នៅយប់នោះខ្លួនបានទៅឆក់ត្រីនៅមាត់ព្រៃបៀតត្រពាំងពារាំង រហូតដល់ម៉ោង ១២ ទើបត្រឡប់មកផ្ទះវិញ រួចចូលសំរាករហូតដល់ម៉ោង ០៣ជិតភ្លឺមានឈ្មោះ **ហ ឃ** បានមកស្រែកហៅចំឈ្មោះខ្លួនបានចេញមកបើកទ្វារមានមនុស្សប្រហែលជា ០៤នាក់ ហ៊ុំព័ទ្ធផ្ទះភ្ជង់នឹងកាំភ្លើងគ្រប់ដៃសំឡុតឱ្យខ្លួនចុះមកដីឱ្យយកប្រដាប់ឆក់ត្រីចុះមកផង ។ ពួកគេបានភ្ជង់ឱ្យខ្លួនដើរទៅត្បូង កន្លែងគេដេកហើយបាននិយាយថា នឹងនាំខ្លួនទៅកន្លែងពារាំង ។ ខ្លួនបាននិយាយសុំអង្វរពួកគេដោយពួកគេសុខចិត្តយកលុយចំនួន ៥០.០០០រៀលគេក៏ឱ្យខ្លួនត្រឡប់មកផ្ទះវិញទៅ ។ អ្នកដែលភ្ជង់សំឡុតខ្លួនមានឈ្មោះ **ហ៊ុល** និង មនុស្ស ០៣នាក់ទៀត មិនស្គាល់ឈ្មោះថា ពេលនេះខ្លួនមិនប្តឹងទាមទារសំណងជម្ងឺចិត្តទេ ។

-ចម្លើយជនរងគ្រោះឈ្មោះ **ហ ឃ** បានឆ្លើយថា កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩ ខ្លួនពុំបានចេញទៅឆក់ត្រីទេ ព្រោះពួគេនិយាយថា មានគេចុះមកចាប់អ្នកឆក់ត្រី ខ្លួនបានដេករហូតដល់ម៉ោង ០២រំលងអធ្រាត្រ កូនរបស់ខ្លួនបត់ជើង ខ្លួនបានចាប់ភ្លើងចុះទៅដងទឹកមាត់ស្ទឹងយកមកលាងចម្ងាយប្រហែល ៥០ម៉ែត្រ រួចប្រពន្ធខ្លួនបានប្រាប់កូនឱ្យដេកវិញ ចំណែកខ្លួននៅអង្គុយជក់បារីនៅលើគ្រែមុខផ្ទះនឹងដី មួយសន្ទុះស្រាប់តែមានមនុស្ស ០៤នាក់ ឯកសណ្ឋានយោធា ០៣នាក់ និង ឯកសណ្ឋានប៉ារ៉ា ០១នាក់ ប្រដាប់ដោយអាវុធគ្រប់ដៃបានមកភ្ជង់គំរាមឱ្យបិទភ្លើងសំឡុតប្រមាថរកចងទៀត និង ទាមទាររកប្រដាប់ឆក់ត្រីខ្លួនបានឆ្លើយថា មានត្រពុំបាន ទៅឆក់ទេ ពួកគេបានដើររកឃើញឱ្យខ្លួនស្ពាយដើរចេញទៅតាម ពួកគេថា ទៅគោកជ្រើង ពេលដើរបានប្រហែលជា ៥០ម៉ែត្រពួកគេបានបង្ខំឱ្យខ្លួនរកលុយឱ្យគេចំនួន ៦០.០០០រៀល ខ្លួនក៏ត្រឡប់មកប្រាប់ប្រពន្ធទៅរកលុយឱ្យពួកគេ លុះបានលុយហើយពួកគេបង្ខំឱ្យជូនទៅផ្ទះឈ្មោះ **ភ រ** ទៀត ដែលនៅខាងជើងផ្ទះរបស់ខ្លួនចម្ងាយប្រហែល ១៥០ម៉ែត្រ ពេលទៅដល់ខ្លួនបានស្រែកហៅឱ្យភ្ញាក់ហើយ ស្រាប់តែកូនរបស់ឈ្មោះ **រិទ្ធ** នៅក្រោយផ្ទះហៅថា ពូ **ហ៊ុល** ហើយឈ្មោះ **រិទ្ធ** អង្វរឈ្មោះ **ហ៊ុល** គេបង្ខំឈ្មោះ **រ** រកលុយឱ្យពួកគេ ៦០.០០០រៀលដែរ ។

-ឈ្មោះ **ខ ស** ប្រពន្ធជនរងគ្រោះបានឆ្លើយថា កាលពីថ្ងៃខែមិនចាំ ក្នុងឆ្នាំ ១៩៩៩ នៅយប់នោះប្តីរបស់ខ្លួនបានចេញទៅឆក់ត្រីរហូតដល់ម៉ោង ១២ ទើបត្រឡប់មកវិញបានចូលដេករហូតដល់ម៉ោង ០៣ជិតភ្លឺបានឮឈ្មោះ **ហ ឃ** មកហៅប្តីខ្លួន ។ ពេលនោះប្តីខ្លួនបានបើកទ្វារចេញមកគេហៅឱ្យយកប្រដាប់ឆក់ត្រីចុះមកផងដោយគេភ្ជង់ឱ្យប្តីខ្លួនដើរទៅត្បូង ប្តីខ្លួននិយាយថា មិនបាច់ភ្ជង់ទេសុទ្ធតែគ្នាឯង គេបានឱ្យដើរទៅដល់ពំនូកចំបើងចុងភូមិចម្ងាយប្រហែល ១.០០០ម៉ែត្រពួកគេទារប្រាក់ ។ ពេលត្រូវគ្នាហើយកូនរបស់ខ្លួនឈ្មោះ **ហឿន** បានរត់មកផ្ទះប្រាប់ខ្លួនថា ពុកឱ្យរកប្រាក់ ៦០.០០០រ០០ ពេលនោះខ្លួនរកប្រាក់បានតែ ៥០.០០០រ០០ យកទៅឱ្យពួកគេក៏យល់ព្រមឱ្យប្តីមកផ្ទះវិញទៅ ។ ខ្លួនមិនស្គាល់ឈ្មោះ តែឮប្តីនិយាយថា ឈ្មោះ **ហ៊ុល** ធ្លាប់ស្គាល់គ្នា ។ ចំណែកឈ្មោះ **ហ ឃ** ពីមុនរស់នៅផ្ទះជិតខ្លួន តែឥឡូវបានប្តូរទីលំនៅទៅនៅភ្នំបូក មិនស្គាល់ភូមិគេទេ ។

## <u>តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា</u>

ឆ្លងតាមការសួរដេញដោលរវាងចម្លើយជនរងគ្រោះ សាក្សី និង ចម្លើយសារភាពរបស់ជនជាប់ចោទរួចមកឃើញថា ឈ្មោះ **ស គហ** ពិតជាបានប្រព្រឹត្តអំពើប្លន់ ដោយខ្លួនជាទាហានមានអាវុធគ្រប់ដៃមានគ្នា០៤នាក់ ទៅសំឡុតទារប្រាក់ពីជនរងគ្រោះ ០២នាក់បានប្រាក់ ១១០.០០០រ០០ ។ មានពិរុទ្ធភាពធ្ងន់ធ្ងរលើឈ្មោះ **ស គហ** ពីបទប្លន់ ប្រព្រឹត្តនៅភូមិអារញ្ញ ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ។

ហេតុនេះសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៦ ទុកជាបានការពេញទាំងមូល ។

សូមតុលាការផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ជនជាប់ចោទឈ្មោះ ស គហ បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-បានស្តាប់ចម្លើយជនជាប់ចោទ

-បានស្តាប់ចម្លើយជនរងគ្រោះ

-បានស្តាប់ចម្លើយសាក្សី

-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-បានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**<u>តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ</u>**

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា</u>**

-ឈ្មោះ ស គហ, ឈ្មោះ ស ធ, ឈ្មោះ ឆ ព និង ឈ្មោះ ជា ធ្វើទាហានសីករងស្រុកសៀមរាប ត្រូវទទួលបញ្ជាទៅបំពេញភារកិច្ចយាមបង្ក្រាបបទល្មើសជលផលឆក់ត្រីនៅត្រពាំងពារវាំង ។ ដល់យប់ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩ ទាំង ០៤នាក់ មានកាំភ្លើងអាកាម្នាក់ ០១ដើម បានទៅសំឡុតជនរងគ្រោះឈ្មោះ ហ ឃ និង ឈ្មោះ ភ រ ដែលមានឧបករណ៍ឆក់ត្រីនៅនឹងផ្ទះ ទារបង្ខំយកប្រាក់ចំនួន ១១០.០០០រ០០ រួចឱ្យជនរងគ្រោះត្រឡប់មកផ្ទះវិញ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ ស គហ មានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-ប៉ុន្តែបើពិនិត្យឱ្យដិតដល់ទៅឃើញថា ជនជាប់ចោទឈ្មោះ ស គហ ជាមនុស្សខ្វះការពិចារណាយកសិទ្ធិ និង តួនាទីទៅបង្ខំជនរងគ្រោះយកប្រាក់ និង ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។

-ជនរងគ្រោះឈ្មោះ ភ រ មិនបានប្តឹងទាមទារសំណងជម្ងឺចិត្តទេ តុលាការមិនលើកយកមកពិចារណា ។

**<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>**

១-ផ្តន្ទាទោសឈ្មោះ ស គហ ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ ( បីឆ្នាំ ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ <u>ប្លន់ តាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល</u> ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ប្រព្រឹត្តនៅភូមិអារញ្ញ ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៩ ។

២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ជនរងគ្រោះឈ្មោះ ភ រ កំបាំងមុខជនរងគ្រោះ ហ ឃ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និង ត្រា
[redacted]

ចៅក្រមជំនុំជំរះ
ហត្ថលេខា និង ត្រា
[redacted]